# មជ្ឈមណ្ឌលឯកសារកម្ពុជា

## *សម្ភាសន៍ជាមួយឈ្មោះ គក់ ប៊ុយ អាយុ៩៣ឆ្នាំ ភេទប្រុស*
## *មុខរបរ ៖ ប្រធានភូមិ*
## *រស់នៅត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ*
## *ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧*
## *សម្ភាសដោយ ៖ វ៉ាន់ថាន់ ពៅដារ៉ា, លី សុខឃាង, សូ ហ្វារីណា និង ណយ សុផារី*
## *ចំនួនទំព័រ ៖ ២២ទំព័រ*

### *កាសែតទី១*
### *ខាងអេ*

ដារ៉ា ៖ ពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកនេះដើម្បីសាកសួរនាំពីទំនប់ត្រពាំងថ្ម ហើយអ៊ីចាំបានប៉ុនណាជម្រាបជូនខ្ញុំប៉ុណ្ណឹងទៅ ។ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះសិន តើអ៊ំឈ្មោះអីដែរ?

ប៊ុយ ៖ គក់ ប៊ុយ ។

ដារ៉ា ៖គក់ ប៊ុយ ។ អាយុប៉ុន្មានឆ្នាំ?

ប៊ុយ ៖ អាយុ៩៣ឆ្នាំ ។

ដារ៉ា ៖៩៣ឆ្នាំហើយ ។ នៅក្នុងភូមិនេះតែម្ដង?

ប៊ុយ ៖ នៅភូមិត្រពាំងថ្មខាងត្បូង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។

ដារ៉ា ៖ ពូនៅតាំងពីណាពីណោមកហើយ ។

ប៊ុយ ៖ បាទ បើនិយាយទៅតាំងពីសម័យសង្គមរាស្ត្រនិយមរបស់ព្រះមហាក្សត្រ ។

ដារ៉ា ៖អូហ៍ នៅបានយូរហើយ ។

ប៊ុយ ៖ បាទ អាយុ៩៣ហើយ ដូច្នេះវាកើតតាំងពីសម័យសីហនុ ។

ដារ៉ា ៖នេះជាស្រុកកំណើតរបស់ពូផ្ទាល់?

ប៊ុយ ៖ បាទ ស្រុកកំណើត ។

ដារ៉ា ៖តើពូមានកូនចៅប៉ុន្មាននាក់ហើយ?

ប៊ុយ ៖ កូនខ្ញុំមាន៦នាក់ ។

ដារ៉ា ៖ ៦នាក់ ។

ប៊ុយ ៖ ក្នុងនោះមានប្រុស៤ស្រី២ ។

ដារ៉ា ៖ បាទ! ហើយកូនបងគេស្រីឬប្រុស?

ប៊ុយ ៖ កូនបងគេប្រុស ។

ដារ៉ា ៖ អាយុប៉ុន្មាន?

ប៊ុយ ៖ អាយុ២៦ឆ្នាំហើយ ធ្វើគ្រូបង្រៀននៅខេត្តឧត្តរមានជ័យ ។

ដារ៉ា ៖ ហើយគ្រួសារពូឈ្មោះអី?

ប៊ុយ ៖ គ្រួសារខ្ញុំឈ្មោះ ជឿន ចន្ថា ។

ដារ៉ា ៖ បានគ្នា (រៀបការ) យូរហើយ?

ប៊ុយ ៖ បានកាលឆ្នាំ៨០ ។

ដារ៉ា ៖ អ៊ីចឹងក្រោយ៧៩?

ប៊ុយ ៖ បាទ!

ដារ៉ា ៖ ពីបានរៀបរាប់ពីខាងដើមថា ពូធ្លាប់បម្រើរបបលន់នល់ ហើយក្រោយមកពេលដែលចូលដល់របបប៉ុលពត របបខ្មែរក្រហម៧៥-៧៩ តើពេលនោះពូធ្វើអី សូមពូជួយរៀបរាប់ពីសកម្មភាពហ្នឹងបន្តិចមក ។

ប៊ុយ ៖ បាទ! កាលពីខ្ញុំអាយុ១៨ឆ្នាំ របបលន់នល់ រើសទាហានដូច្នេះមួយឃុំប៉ោចាររនេះចាប់ឆ្នោតដល់ខ្ញុំចាប់ឆ្នោតទៅជាប់ធ្វើជាទាហាន ហៅថាកងស្វាយត្រានដល់ផុតពីស្វាយត្រានទៅ ចូលធ្វើទាហានបណ្តោយ ។

ដារ៉ា ៖តើពេលនោះឆ្នាំណា?

ប៊ុយ ៖ ឆ្នាំ១៩៧២ ។

ដារ៉ា ៖ អូហ៍ ។

ប៊ុយ ៖ ឆ្នាំ១៩៧២ ខ្ញុំបម្រើនិន្នាការនយោបាយរបបសាធារណរដ្ឋខ្មែរ កាលហ្នឹង ។ ដល់ឆ្នាំ១៩៧៥ របបនោះត្រូវផ្តួល [រំលំ] ដែលមានប៉ុលពតកាន់កាប់ របបកម្ពុជាប្រជាធិបតេយ្យ ពេលនោះខ្ញុំនៅវ័យលីវមិនទាន់បានគ្រួសារទេ នៅជាយុវជនដូច្នេះខ្ញុំដើរចល័តណា មួយជុំវិញតំបន់៥ ដូច្នេះតំបន់៥គឺមាននៅបន្ទាយមានជ័យដែលសព្វថ្ងៃយើងហៅថាស្វាយ[ស៊ីសុផុន] ។ កាលពីមុនហៅថាតំបន់៥ ខ្ញុំដើរចល័តពេញណាពេញណៃ ។

ដារ៉ា ៖ តើពូធ្វើយ៉ាងម៉េចទើបអាចលាក់ប្រវត្តិហ្នឹងបាន?

ប៊ុយ ៖ ខ្ញុំកាលហ្នឹងជាប់និន្នាការ ប្រសិនបើខ្ញុំមិនលាក់ប្រវត្តិទេ ពេលដែលនៅមូលដ្ឋានរបស់ខ្ញុំ ខ្ញុំប្រាកដជាបាត់ខ្លួន ។ ដូច្នេះអ្នកដែលធ្វើទាហានមួយស្រុកខ្ញុំដែលនៅទីនេះ ស្លាប់អស់ច្រើននាក់ណាស់ ដែលបានប្រពន្ធទៅមិនបានទៅណា នៅក្នុងភូមិនេះក៏ស្លាប់ ។ នៅភាគតិចណាស់ដែលមិនទាន់ស្លាប់ ។ ដូច្នេះរាល់មេ (ប្រធាន) មួយដែលនៅកាន់កាប់ខ្ញុំក្នុងរបបពាឆ្នាំ ខ្ញុំចេះតែលាក់ប្រវត្តិរូប កាលហ្នឹងយើងដាក់ថាធ្វើទាហានដែរ ប៉ុន្តែប្រាប់ថាធ្វើតិចតួច ពេលដែលមេមួយដែលមកគ្រប់គ្រងខ្ញុំគេសួរខ្ញុំ ខ្ញុំប្រាប់ថា ធ្វើទាហាន៣ខែ ដល់ផ្លាស់មេថ្មីចូលមកទៀតគេស្រាវជ្រាវប្រវត្តិរូបទៀត ខ្ញុំដាក់មួយខែ ថាធ្វើទាហាន១ខែទើបសន្តិភាព ។ ដល់ពេលផ្លាស់មេមួយទៀតមកចូលមេថ្មីទៀត ខ្ញុំដាក់ថា ធ្វើស្វាយត្រានក្នុងភូមិ ។ ពេលចូលដល់ឆ្នាំ១៩៧៨ ខ្ញុំដាក់ថាប្រជាជនធម្មតា ទើបខ្ញុំរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។ ដល់មានរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាចូលមកដល់ទើបខ្ញុំបានរស់ ។

ដារ៉ា ៖ បាទ! ពូលាក់ប្រវត្តិរូប បើនិយាយឲ្យចំទៅ ពូភរគេតែម្តងហ្នឹងណា តើខ្មែរក្រហមដែលឡើងមកកាន់កាប់ក្រោយៗមកទៀតអត់មានតាមដានរកមើលសួរថាប្រវត្តិពូពិតមិនពិតអីអត់ទេ?

ប៊ុយ ៖ តាមរហូតដល់សួរគ្រួសារខ្ញុំ សួរពីជីវប្រវត្តិរបស់ខ្ញុំ សួរគ្រួសារខ្ញុំ គ្រួសារខ្ញុំក៏ជួយលាក់ប្រវត្តិខ្ញុំហើយក្រោយមកទៀតគេសួរប្រវត្តិរបស់គ្រួសារខ្ញុំវិញ ខ្ញុំក៏ជួយលាក់ណ៎ា ទៅវិញទៅមក ទើបគេមិនអាចរកឃើញ កុំអីពួកយើងស្លាប់អស់ហើយ ។

ដារ៉ា ៖ ចុះម៉េចបានភរស៊ីសន្ទាក់គ្នាកាលហ្នឹង?

ប៊ុយ ៖ មិនដែលបានជួបគ្នាទេ ដូចថាយើងជាអ្នកភូមិផងរបងជាមួយនៅជាមួយគ្នា ដូចថាខ្ញុំនៅទីនេះហើយគ្រួសារខ្ញុំនៅខាងនោះ ។ យើងចេះតែជួយគ្នា ។ ប៉ុន្តែខ្ញុំកាលហ្នឹង...សព្វថ្ងៃនេះគេប្រើអាយកូម ដល់កាលនោះគេប្រើ**សេវាំងសែង**របស់អាមេរិកាំងទម្ងន់៨គីឡូ ដូច្នេះខ្ញុំកាន់សេវាំងសែងមានកាំភ្លើងខ្លី១ដើម ។ ដល់ទាហានកាលនោះអ្នកកាន់តេអូមានកាំភ្លើងខ្លី អ្នកកាន់កាំភ្លើងធំក៏មានកាំភ្លើងខ្លីដែរ សម្រាប់បាញ់កម្ទេចចោលពេលណាដែលមានអាសន្នអន់ក្រ បាក់ទ័ពរត់មិនរួចត្រូវបាញ់ចោលណ៎ា ដូចជាតេអូយើងដកយកតែ**កុំណេ** គឺបាញ់កម្ទេចហ្វេកង់វាចូល ដូចជាអាសេវេនអីកាំភ្លើងកែវាបាញ់ចោល ។

ដារ៉ា ៖ ដល់ពេលឆ្នាំ៧៥ ពូចូលបម្រើខ្មែរក្រហម?

ប៊ុយ ៖ បាទ! ចូលបម្រើខ្មែរក្រហមនៅជាកងចល័ត ។

ដារ៉ា ៖ អ៊ីចឹងពូដើរធ្វើការនៅក្នុងតំបន់ហ្នឹង?

ប៊ុយ ៖ បាទ ដើរចូលធ្វើការនៅក្នុងតំបន់នេះ ។ មុននឹងដើរធ្វើការ ខ្ញុំនៅមូលដ្ឋាននេះរយៈពេលមួយឆ្នាំ ដើរចល័តដូចថាដើរធ្វើប្រព័ន្ធភ្លឺស្រែតាមនេះ ។ ដល់រួចទៅក្នុងនាមខ្ញុំចេះតែកសាងខ្លួន ធ្វើការអ្វីមួយអត់មានទារុនស្មុក់ ព្រោះយើងដឹងថាខ្លួនយើងជាប់និន្នាការ យើងត្រូវតែប្រឹងខំធ្វើយ៉ាងណាឲ្យគេស្រលាញ់យើងថាយើងធ្វើការដោយពិតប្រាកដមែន រហូតដល់ខ្ញុំជាប់ជាថ្នាក់ដឹកនាំគេ ។ កាលហ្នឹងមានបងប្អូនពីភ្នំពេញ (ប្រជាជនជម្លៀស) មកកន្លែងនេះដែរហើយមុននោះក៏ខ្ញុំជាថ្នាក់ដឹកនាំក្នុងក្រុម ដល់ក្រុមមកធ្លាក់ដល់ភូមិរហូតដល់ខ្ញុំកាន់មួយសហករណ៍ គ្រាន់តែកាន់ខាងយុវជន ហើយនារីគេមានមេគេផ្សេង ដល់ខ្ញុំមានយុវជនកាន់មួយសហករណ៍ហៅថា ប្រធានវរៈ ។ ដល់ក្រោយពីនោះទៅ ឆ្នាំ ចុងឆ្នាំ៧៦ទើបដកខ្ញុំចូលចល័តតំបន់ ដល់ពេលចូលចល័តតំបន់ខ្ញុំនៅជាប្រធានកងតូច ។

ដារ៉ា ៖ កងតូចនោះប៉ុន្មាននាក់ទៅ?

ប៊ុយ ៖ ៣០នាក់ ។

ដារ៉ា ៖ ៣០នាក់ ។

ប៊ុយ ៖ បាទ មាន៣ក្រុម ក្នុង១ក្រុម១០នាក់ ដល់៣ក្រុមស្មើនឹង៣០នាក់ហើយប្រធានកងតូច៣នាក់ទៀត ទាំងអស់៣៣នាក់ ។

ដារ៉ា ៖ ចល័តហ្នឹងបើតាមស្តាប់ទៅដូចជារចនាសម្ព័ន្ធទាហានអ៊ីចឹង វរៈសេនាតូចអី ប៉ុន្តែអត់កាន់កាំភ្លើងទេ?

ប៊ុយ ៖ បាទ! បើនិយាយពីអាវុធមានតែចប បង្គី ដងរែក ដូចជាទាហានអ៊ីចឹងឯង តម្រង់ជួរឡើងត្រង់ដ្ឋឹង គ្រាន់តែស្រែកកញ្ច្រែទ្រេតតម្រង់ជួរឡើងត្រង់ អត់មានឲ្យអន្តុយអីទេ ដូចជាទាហានអ៊ីចឹង ដូចខ្ញុំថា៣៣នាក់មួយកងតូចចូលភ្លាមៗ អ្នកណាចំមុខព្រួញអ៊ីចឹងដូចប្អូនឯងថាចំមុខនេះហើយដាក់បង្គីចបភ្លាមៗ ។

ដារ៉ា ៖ តើនៅក្នុងឆ្នាំ១៩៧៦ ប្រធានតំបន់ឈ្មោះអី?

ប៊ុយ ៖ កាលហ្នឹងឈ្មោះតាវ៉ាល់ ។ សេង វ៉ាល់ ។ និយាយទៅគេហៅថាមេឃាតករផ្ទាល់តែម្តងណា ។

ដារ៉ា ៖ តាវ៉ាល់?

ប៊ុយ ៖ បាទ! ព្រោះគាត់ដូចជាមេគេណា មានក្រោមៗទៀតដូចជាសេនាដៃស្តាំសម្រាប់ធ្វើបាបជនណាដែលទារុណស្មុក់ស្ពឹកស្រពន់នឹងការងារពលកម្ម ឧបមាថាគេដាក់ផែនការទៅហើយ យើងធ្វើចុងដៃចុងជើងនោះគេដកដូចកូនស្ពៃ យកទៅវាយចោលឯងៗ ដូចថាមិនមានកំហុសអីទេ គ្រាន់តែគ្នាធ្វើ ហើយមេនោះមិនសូវពេញចិត្តដកទៅហើយ ។ ឲ្យតែពុតែឃ្លួននិងចិនអត់មានទៅទេ ។

នេះគេ (ប្រពន្ធ) នៅក្មេងរាងសខ្ចី គេថាកូនចិន ។ គាត់មិនមែនកូនចិនទេ គ្រាន់តែថាប៉ាគេនៅខាងតាកែវនោះទៅ ប្រហែលជាប់ខ្សែចិនមិននឹង ។

ដារ៉ា ៖ អាចថាគ្រួសារពូសាច់ស ៗ ទៅគេថាចិនណា៎ ។

ប៊ុយ ៖ បាទ! កាលនោះអត់បានទេ ឲ្យតែពូថាចិននិងវៀតណាម គេដាក់ទាំងឡាន ៗ យកទៅកម្ទេចចោល ។

ដារ៉ា ៖ ហើយមានចិនមានអីនៅម្តុំហ្នឹងដែរកាលពីជំនាន់ពូទៅចល័តទៅអី?

ប៊ុយ ៖ បាទ! មានចល័ត និយាយទៅបងប្អូនយើងមួយចំនួនដែលនៅភ្នំពេញណា គេជម្លៀសមកធ្លាក់មកដល់នេះមានចិនមានអីដែរ ។ ខ្លះចិន ហើយធ្វើពលកម្មរាងស្មុគស្មាញបន្តិចទៅក៏បាត់ខ្លួន ហើយចិនណាដែលធ្វើពលកម្មមាំមួនដូចគេដូចឯង ដូចអ្នកមូលដ្ឋានក៏បានរស់រានមានជីវិតរហូតដល់ត្រឡប់ទៅស្រុកទៅស្រែវិញ ។

ដារ៉ា ៖ អ៊ីចឹងនៅឆ្នាំណាទើបពូបានមកធ្វើការងារ លើកទំនប់ត្រពាំងថ្ម?

ប៊ុយ ៖ នៅឆ្នាំ...និយាយទៅថា ចុងឆ្នាំ១៩៧៧ គឺដកខ្ញុំពីដកខ្ញុំពីការដ្ឋាភូមិរំចេកយកមកនៅអាងត្រពាំងថ្ម មានមួយវរៈសេនាតូចដែលក្នុងនោះប្រធានវរៈសេនាតូចខ្ញុំឈ្មោះ មិត្តបូ ប៉ុន្តែមិនដឹងថា ស្អីបូទេ ខ្ញុំភ្លេចទៅវាយូរអង្វែងទៅហើយ ។ ប៉ុន្តែក្នុងនោះស្លាប់ទៅហើយដោយសារគេដកមកពីខាងតាកែវកំពត គេហៅថាខាងនិរតី គេមកកម្ទេចពាយ័ព្យចោល បើសិនមិនបានកម្ទេចពាយ័ព្យទេ វាអត់មានអំណាចគ្រប់គ្រងកាន់កាប់នៅនឹងដៃទេ ដូច្នេះសម័យកាលនោះបើនិយាយទៅថា វាដណ្តើមអំណាចគ្នា កាលដែលនៅទីនេះសុទ្ធតែពាយ័ព្យម្ចាស់មូលដ្ឋានគេកាន់កាប់គ្រប់គ្រងតាំងពីភូមិឃុំស្រុកណា ។ គណៈឃុំគណៈស្រុកសុទ្ធតែពាយ័ព្យ ដល់ពេលឆ្នាំ៧៧បានយកខាងកំពង់ឆ្នាំង ខាងបស្ចឹម ពួកខ្មៅៗកំពង់ឆ្នាំងមិនសូវសដូចខាងនិរតីទេ ។

ដារ៉ា ៖ នេះខាងកំពង់ឆ្នាំង ។

ប៊ុយ ៖ អូហ៍...។ គេហៅថាបស្ចឹមប្រទេស ភូមិភាគបស្ចឹមយកមក ដល់ភូមិភាគបស្ចឹមនោះវាយចោលពាយ័ព្យខ្លះ ក៏នៅគ្រប់គ្រងជុំគ្នាខ្លះ ដល់ទីបំផុតគេយកភូមិភាគនិរតីមកគ្រប់គ្រងម្តងទើបសម្លាប់តាំងពីកំពង់ឆ្នាំង បន្ទាយមានជ័យ អូហ៍កាលហ្នឹងគេហៅថាបាត់ដំបង ។ ពេលនោះគេចាប់ផ្តើមគ្រប់គ្រងអំណាចតាំងពីគណៈភូមិសហករណ៍ ស្រុកនិងតំបន់ ។

ដារ៉ា ៖ គឺភូមិភាគនិរតីទាំងអស់?

ប៊ុយ ៖ បាទ! ភូមិភាគនិរតីគ្រប់គ្រងទាំងអស់ ដូចជា យាយបែម តាម៉ុក ណា៎ ជាអ្នកគ្រប់គ្រងនៅកន្លែងនេះ ។

ដារ៉ា ៖ ពូធ្លាប់ស្គាល់យាយថែមទេ?

ប៊ុយ ៖ មិនស្គាល់ទេ ព្រោះគាត់មិនមែននៅនេះទេ គាត់នៅខាងភ្នំលាប បើនិយាយទៅ នៅខាងស្រុកព្រះនេត្រព្រះ សូម្បីតាម៉ុកខ្ញុំមិនដែលស្គាល់ គាត់នៅខាងតំបន់ ខាងភូមិភាគ ។

ដារ៉ា ៖ កាលដែលពូធ្វើការនៅទំនប់ត្រពាំងថ្ម តើធ្លាប់ឮឈ្មោះយាយថែមទេ?

ប៊ុយ ៖ បាទ! ឮថាយាយថែម ។

ដារ៉ា ៖ កាលឮល្បីជំនាន់ហ្នឹង ពូមានអារម្មណ៍ថា គាត់កាចឬស្លូតអីយ៉ាងម៉េច?

ប៊ុយ ៖ បាទ! កាច សូម្បីតែតាវ៉ាល់ជាប្រធានភូមិភាគពាយ័ព្យនេះក៏គាត់កាចណាស់ដែរ ដល់ពេលនោះមកគេក៏ចាប់តាវ៉ាល់ទៅ ហើយសេនាដៃស្ដាំរបស់គាត់ក៏ទៅបណ្ដើរៗ រហូតដល់ខ្ញុំដេកមិនលក់បក់មិនល្ហើយមួយយប់ទាស់ព្រឹក ព្រោះខ្ញុំខ្លាចជាប់ដល់ខ្លួនខ្ញុំទៅទៀតព្រោះក្នុងនាមខ្ញុំជាអនុពេលនោះខ្ញុំឡើងជានេះហើយ ឡើងជាកងតូចទៅកងធំហើយ ខ្ញុំនៅជាអនុប្រធានគេ ខ្ញុំខ្លាចខ្លាចដោយ ដូច្នេះគេយកត្រឹមវរៈទៅ ហើយកងធំនៅទាំងអស់គ្នា ដូច្នេះកងធំណាមួយចំនួនដែលជាបក្ខពួករបស់គាត់ ជាតាវ៉ាល់ណា ដែលជាប់ជាមួយហើយគ្រាន់តែធ្មេចតែភ្នែកបានការបណ្ដោយក៏បាត់ខ្លួនទៅទាំងអស់គ្នា ហើយមេកងធំណាដែលនៅដាច់ដោយឡែកហ្នឹងក៏រស់នៅមានជីវិត ដល់ឆ្នាំចាប់តាវ៉ាល់រួច ឆ្នាំ១៩៧៨ក៏បាននិរតីចុះមក ហើយមេដែលគ្រប់គ្រងមួយតំបន់នេះគឺឈ្មោះ យន់ ។

ដារ៉ា ៖ យឿន?

ប៊ុយ ៖ យន់ ។ កាលហ្នឹងដកមកពីភូមិភាគនិរតី គាត់កាន់ផ្នែកខាងទ័ពផ្ទាល់ណា នៅភូមិភាគនិរតីគេយកមកក្ដាប់មួយតំបន់ ជំនួសតាវ៉ាល់ ។ កាលហ្នឹងចល័តតំបន់មួយកន្លែងតំបន់៥ គឺនៅលើគាត់គ្រប់គ្រងឈ្មោះ យន់ ។ ហើយបន្ទាប់មកដែលកាន់កាប់មួយវរៈគឺតានិន ហើយតាចេង តានិននិងតាចេងគាត់ជាប្រធានវរៈខ្ញុំ ហើយពេលប្រហែលជាខែ៦ឬខែ៥ ទើបដកតាចេងចេញពីខ្ញុំទៅ គាត់ទៅនៅកាន់ខាងម៉ៃវ៉ា (ប្រពន្ធខ្ញុំ) ហើយគ្រួសារខ្ញុំនៅខាងនេសាទ តំបន់នោះ ។ ដល់ពេលគេកាន់ទៅ ធ្វើទៅស្គាល់គ្នា យើងក៏សួរ ។ កាលហ្នឹងគាត់នៅទីនេះទេ ខ្ញុំសុំគាត់ថា "បងខ្ញុំស្នើគ្រួសារ" គាត់សួរខ្ញុំថា "ក្មួយឯងស្នើនៅឯណា?" "ខ្ញុំមិនមែនស្នើនៅទីនេះទេ នៅអង្គភាពនេសាទ" "ស្គាល់គ្នាទេ?" "ស្គាល់ ព្រោះភូមិជិតគ្នាហើយម៉ែឪទុកដាក់តាំងពីតូចៗមក បើនិយាយទៅតាំងពីមិនទាន់កើត ។ ដល់ពេលនេះគាត់ស្លាប់ចោលអស់ទៅចង់សុំស្នើបងយកគាត់ជាគ្រួសារ" ខ្ញុំស្នើពីរបីដង ។ គេតាមដានខ្ញុំណាស់ កាលហឹងគ្រាន់តែឮថាយើងស្គាល់គ្នាគេដើរតាមដានខ្ញុំ ។

ដារ៉ា ៖ អូហ៍ ។

ប៉ុយ ៖ បាទ! កាលហ្នឹង៧៨ ខែ៧ ខែ៨ កំពុងតែតាមដានខ្ញុំពីរនាក់ គេក៏លាក់ជីវប្រវត្តិរបស់ខ្ញុំដែលខ្ញុំធ្វើទាហានហើយខ្ញុំក៏លាក់របស់គេដែរ និយាយតាមត្រង់ ។ ខ្ញុំថា «បើបង់ឯងមិនជឿសួរចុះ» ដល់ឆ្នាំ១៩៧៨ ខែ៦ ទើបដកខ្ញុំចេញពីអាងទៅធ្វើកប្បាសនៅស្វាយស៊ីសុផុន ។

ដារ៉ា ៖ ខ្ញុំចង់សួរត្រឡប់ថយក្រោយបន្តិចទាក់ទងនឹងការធ្វើការនៅត្រពាំងថ្មហ្នឹងណា៎ ពូអាចដឹងទេថាតើទំនប់ហ្នឹងមានតាំងពីឆ្នាំណាមក?

ប៉ុយ ៖ ទំនប់នោះមានតាំងពីឆ្នាំ១៩៧៦ នោះគ្រាន់តែគេជួសជុលទេ គេជួសជុលកន្លែងណាដាច់ៗ ដល់ចុងឆ្នាំ១៩៧៦ យើងចាប់ផ្តើមធ្វើហើយ ។

ដារ៉ា ៖ កាលហ្នឹងយុទ្ធនាការធំនៅចុង៧៦?

ប៉ុយ ៖ បាទ! ដើម៧៦នោះគ្រាន់តែដកចល័តតំបន់មកបំពេញកន្លែងដែលដាច់ៗនៅតាមស្ពាន តាមផ្លូវចាស់ដែលមានដាច់ធំៗទៅគេគ្រាន់តែយកយុវជន តាំងពីនារី តាំងពីកុមារា កុមារី កូនក្មេងតូចៗយកទៅ ហើយស្មើនេះនៅវែកដី រៀបចំមួយកង១ ។

ដារ៉ា ៖ ពេលដែលពូទៅដល់ តើឃើញសភាពយ៉ាងម៉េចដែរ នៅកន្លែងទំនប់ត្រពាំងថ្មនោះ ជាមនុស្សកុះករឬយ៉ាងម៉េច?

ប៉ុយ ៖ បាទ! ដូចម្រាមដៃ វាណែណាន់តាន់តាត់ ដូច្នេះចល័តតំបន់មាន១កងនៅណា ហើយចល័តស្រុកដែលមាន៥ស្រុកនោះមាន៥កងទៅ មើលទៅជាប់គ្នា ដូច្នេះគេបោះបង្គោល១ៗ ដូច្នេះចល័តដែលគ្នារស់នៅដែលវេទនាគេធ្វើរោងឲ្យនៅតាមវាលស្រែ តាមកន្លែង ដល់ពេលនេះទៅវាជួបផលលំបាកដូចថាវាប៉ះពាល់ដល់សុខភាព វាមានសត្វរុយរោមអាហារអីហ្នឹងទៅ បើនិយាយពីម្ហូបអាហារវិញ គឺមានត្រីផ្អៀតដែលគេដឹកតាមឡានមក មិនបានយកតង់កៅស៊ូដាក់ក្រាលទេគឺដីអីចេះហើយ បារទម្លាក់ចោលនៅលើដីតែម្តង ។ វេទនាបំផុត ប៉ុន្តែប្រសិនបើយើងថា ខ្ទើមរអើមឬកបន្តិចគឺត្រូវដាក់ពោះស្លាប់សុខចិត្តហូប ។

ដារ៉ា ៖ ត្រូវតែហូប ។

ប៉ុយ ៖ បាទ ។

យ៉ាង ៖ ពូនិយាយអម្បាញ់មិញថា យាយចែមជាមនុស្សកាច កាលនោះពូដឹងដោយសារអីដែរ?

ប៉ុយ ៖ ទេ កាលហ្នឹងយើងឮគេនិយាយតគ្នាថាកាចណាស់យាយចែម ។

យ៉ាង ៖ កាចយ៉ាងម៉េចខ្លះ?

ប៊ុយ ៖ កាចនេះគឺគំរាមកំហែងវាយមនុស្សចោល គ្រាន់តែធ្វើអីខុសតែបន្តិចបន្តួច ដូចថាស៊ីកស្រពន់នឹងការងារដូចថាធ្វើការទៅដូចថាធ្វើឡេះឡោះ នឹងបាត់ខ្លួនហើយ ។

ដារ៉ា ៖ តើនៅក្នុងភូមិនេះមាននរណាមួយដែលធ្លាប់រងគ្រោះអីដោយសារយាយថែមទេ?

ប៊ុយ ៖ ទេ ខ្ញុំថាយាយថែមហ្នឹងមិនបាននៅក្នុងតំបន់នេះទេ ។

ដារ៉ា ៖ខ្លាចក្រែងមានអ្នកណាមួយអីធ្លាប់នៅកន្លែងក្រុមកងយាយថែម ប៉ុន្តែគាត់នៅរស់រានមានជីវិតទៅគាត់មកនៅក្នុងភូមិនេះអី?

ប៊ុយ ៖ អត់មានទេ បើមាន មានតែអ្នកនៅជុំយាយថែម ពេលដែលវៀតណាមចូលមកដល់នោះមានអ្នកនៅជាមួយណា ដូចថាធ្វើយោធា ដំបូងធ្វើចល័តដល់ពេលចូលមកស្រុកវិញ ដល់ពេលពួកខាងយាយថែមបានវាយវៀតណាមបកទៅណោះវិញ ទើបគៀរប្រជាជនមួយចំនួនយកទៅដូច្នេះគេរើសយកយុវជនៗទៅ បុកចូលព្រៃ នោះទើបនៅជុំយាយថែម មាននៅនោះសព្វថ្ងៃ ។

ដារ៉ា ៖ ចុះរឿងម៉ោងពេលធ្វើការងារនៅកន្លែងទំនប់ត្រពាំងថ្មហ្នឹង តើចាប់ផ្តើមពីម៉ោងប៉ុណ្ណាដល់ម៉ោងប៉ុណ្ណា ហើយឈប់សម្រាកអីពីម៉ោងណាដល់ម៉ោងណា?

ប៊ុយ ៖ ចាំមើលណា អារឿងឈប់សម្រាកវាមានពេលកំណត់របស់វា ឧទាហរណ៍ថា គេចែកជា៣ ម៉ោង៦ចាប់ផ្តើមធ្វើការ ។

ដារ៉ា ៖ ព្រឹក?

ប៊ុយ ៖ បាទ! ព្រឹកក៏បានល្ងាចក៏បាន ។ ខ្ញុំនិយាយល្ងាចទៅចុះ ម៉ោង៦ចាប់ផ្តើមធ្វើការដល់ម៉ោង១២យប់ នេះត្រូវផ្លាស់មួយកង ហើយម៉ោង១២យប់ដល់ម៉ោង៦នោះត្រូវផ្លាស់មួយកង ។ ដល់ម៉ោង៦ទៅម៉ោង១២នោះផ្លាស់មួយកងទៀត ។ វិលចុះឡើង ។ ដូច្នេះការធ្វើចលនាពលកម្មអត់ឲ្យមានសម្រាកទេ គឺដំណើរការដើររហូត ។ ប៉ុន្តែអ្នកធ្វើការមានសម្រាកណា ដល់ម៉ោង១២យើងស្រុះស្រួបអាហារ ។

ដារ៉ា ៖ ក្នុងកំឡុងពេល ឧបមាថាពីម៉ោង៦ដល់ម៉ោង១២ មួយដំណាក់ៗហ្នឹងធ្វើអត់មានឈប់សោះឬមានចន្លោះណាមួយ...?

ប៊ុយ ៖ អត់មានឈប់ទេ គឺស្ទួរចបលាន់រំពង ។

ដារ៉ា ៖អត់មានទៅហូបបាយហូបទឹកទេ?

ប៊ុយ ៖ អត់ទេ នោះមួយវគ្គ ដល់មួយវគ្គទៀត ពីម៉ោង៦ទៅម៉ោង៦ព្រឹកអត់មានបានដេកទេ ។

ដារ៉ា ៖ តើនោះជាវគ្គយ៉ាងម៉េចទៅ?

ប៊ុយ ៖ នោះគឺថា... ។

ដារ៉ា ៖ កម្លាំងមកពីខាងណាទៅ?

ប៊ុយ ៖ ណែ គេរៀបចំចម្រាញ់ឈប់ឲ្យមានបញ្ហានេះហើយ អាផ្លាស់ប្តូរពីម៉ោង៦ដល់ម៉ោង១២ ដូច្នេះគេចាប់ផ្តើមយកពីម៉ោង៦ល្ងាចដល់ម៉ោង៦ព្រឹក ដល់ពេលគេរើសអ្នកដែលល្ងិត(ខ្វាក់)មាន់ អីដែលមិនអាចធ្វើការងារកើតនៅពេលយប់ ទើបគេរើសយកអ្នកល្ងិតមាន់ឲ្យធ្វើការងារថ្ងៃ ហើយអ្នកណាដែលមានភ្នែកភ្លឺធ្វើការងារយប់ ដូច្នេះផែនការនេះផ្លាស់ប្តូរពីម៉ោង៦ដល់ម៉ោង១២ គេកែប្រែកម្មវិធីយកអាអ្នកល្ងិតមាន់ៗ កាលណោះមានដែរ ព្រោះយើងខ្វះជាតិ...ការហូបចុកអត់គ្រប់គ្រាន់ណាៗ ដូច្នេះមានការល្ងិតមាន់ បើកាលណាប៉ះថ្ងៃទៅល្ងិតៗ មានមែន ខ្ញុំឃើញអ្នកល្ងិតមាន់ ពេលដល់មានខែភ្លឺមក មើលទៅតែខែ យើងចេះតែដើរ ជួនកាលធ្លាក់អន្លង់ អត់ដឹង ព្រោះគ្នាមើលទៅតែលើ ចុះមើលក្រោមអត់ឃើញៗ ពីម៉ោង៦ទៅម៉ោង៦ព្រឹកនេះ មួយយប់ហ្នឹងគឺធ្វើរហូត ប៉ុន្តែមិនមែនធ្វើជាប់ទេ មានពេលសម្រាក អត់មានហូបបាយទេ ដូចថាយើងធ្វើរយៈពេល២ម៉ោង ដូចថាគេឲ្យយើងសម្រាកពី៥នាទីទៅ១០នាទី ឲ្យយើងផឹកទឹក ឬហូបបារីហូបអី ដល់នេះរួចគេស្រែថាចុះទៀត យើងចុះទៅទៀត ដល់ម៉ោង៦ព្រឹកចាប់ផ្តើមឈប់ អាកងថ្ងៃចាប់ផ្តើមបន្តទៅទៀតហើយ គេហៅថាកងខ្វាក់មាន់ៗ គេធ្វើបន្តដល់ម៉ោង១១ បានកងថ្ងៃហូបបាយ ដល់ម៉ោង១ចុះទៅវិញៗ

ដារ៉ា ៖អ៊ីចឹង២៤ម៉ោងគឺដើរទាំង២៤ម៉ោង?

ប៊ុយ ៖ បាទ! ដើរទាំង២៤ម៉ោង ប៉ុន្តែបើនិយាយពីខ្លួនយើងគឺដើរតែ១២ម៉ោងទេ បើថាខ្ញុំធ្វើយប់ធ្វើម៉ោង៦ល្ងាចចាប់ផ្តើមធ្វើដល់ម៉ោង៦ព្រឹក ហើយពេលថ្ងៃយើងសម្រាន្តវាស់ល្ងាចៗ

ដារ៉ា ៖យើងបានសម្រាកអត់ធ្វើការងារអីផ្សេងទេ?

ប៊ុយ ៖ អត់ធ្វើអីទេ គិតតែនេះទៅ ដល់រួចទៅយើងងូតទឹកចងមុងចងអីដេកៗ ពេលនោះខែប្រាំងរុយច្រើនណាស់ៗ និយាយពីរុយដូចឃ្មុំៗ

ដារ៉ា ៖អូហ៍ៗ ចុះការហូបចុក តើរបៀបរបបហូបចុកអីយ៉ាងម៉េចដែរ?

ប៊ុយ ៖ រឿងហូបចុកមិនសូវជាខ្វះខាតប៉ុន្មានទេ ប៉ុន្តែយើងទទួលទានទៅវាអត់បានទេ វាហេវវាហត់ទៅហួសពីការនេះទៅ វាបាក់កម្លាំងៗ ម្ហូបគេមានត្រីងៀត មានបាយពេលនោះអត់មានបបរទេៗ ប៉ុន្តែបាយនោះចត់អស់ទៅហើយ យើងហូបមិនកើតទេ វាចត់បាយៗ រហូតដល់មេកាស៊ីន (ចុងភៅ) ដើរដាស់តាមកន្លែងឲ្យឡើងហូប បើសិនជាមិនដាស់ទេ ត្រូវអត់ផងុយហើយអត់បាយទាស់ព្រឹកៗ ហើយតាំងពីអ្នកធ្វើការថ្ងៃក៏ហូបចត់ទាំងអស់គ្នាៗ

ដារ៉ា ៖ កាលហ្នឹងហូបរួម?

ប៊ុយ ៖ បាទ! ហូបរួម ។

ដារ៉ា ៖ ហើយការអនាម័យអីយ៉ាងម៉េចដែរ ពូមាននិយាយថា កាលហ្នឹងរុយច្រើនអីយ៉ាងម៉េច?

ប៊ុយ ៖ អត់មានអនាម័យទេ មិនមានទេ ដូចខ្ញុំនិយាយថា ត្រីអត់មានយកគត់យកអីដាក់ក្រាលទេ គឺបារទម្លាក់ពីឡានមក ។ ពេលដែលទម្លាក់ហើយគេហៅមកដូចថាមួយវេរៈ ដូចយើងសព្វថ្ងៃយើងហៅថាភស្តុភារទៅទទួលបើកតាំងពីអង្ករតាំងពីប្រហុក ត្រីងៀត យកមកទើបចែកចាយទៅតាមកងតូចកងធំ ។

ដារ៉ា ៖ អ៊ីចឹងការរស់នៅពេលមានរុយមាន អាចសម្គាល់ឃើញបានទេថាអ្នកលើកទំនប់ទាំងអស់ហ្នឹងជួបជំងឺឈឺថ្កាត់អីភាគច្រើន តើជំងឺអីខ្លះទៅអាចដឹងទេ?

ប៊ុយ ៖ មានតែជំងឺរាករុស ។

ដារ៉ា ៖ រាករុស ។ អាហ្នឹងខ្លាំងជាងគេ?

ប៊ុយ ៖ បាទ រឿងរាករុសខ្លាំង ពេលក្តៅទៅផឹកទឹក ហើយណាមួយរុយរោមតាមអាហាររបស់យើង ។

ដារ៉ា ៖ តើជំនាន់ហ្នឹងមានរុយមកពីណា?

ប៊ុយ ៖ អូហ៍ច្រើនណាស់ដូចឃ្មុំ មិនដឹងមកពីណាទេ ។

យាង ៖ ចុះដល់ពេលយើងរាកអ៊ីចឹងគេបញ្ជូនទៅពេទ្យអីយ៉ាងម៉េច?

ប៊ុយ ៖ គេបញ្ជូនទៅពេទ្យ មានថ្នាំរបស់គេ ។ គេហៅថាអាចម៍ទន្សាយណា ។

យាង ៖ ពេទ្យនោះត្រឹមត្រូវទេ តាមលក្ខណៈបច្ចេកទេសទេ?

ប៊ុយ ៖ ធ្វើយ៉ាងម៉េចទើបត្រឹមត្រូវបើពេទ្យ...គ្រាន់តែដាក់បញ្ចូលបានតែមួយចេះៗ គេថាបើកថ្នាំឲ្យគេក៏បើកទៅ ។

ដារ៉ា ៖ មិនដឹងថាថ្នាំនោះត្រូវអីមិនត្រូវអីទេ?

ប៊ុយ ៖ បាទ! ដូចថាថ្នាំនោះថាឈឺពោះ ឈឺក្បាលអីក៏បានថ្នាំនោះតែមួយមុខហ្នឹង មិនមានអ៊ីផ្សេងទេ និយាយទៅពេទ្យគ្មានមុខជំនាញទេ គឺយកមកពីតាមភូមិគ្រាន់តែក្នុងនាមជាអង្គភាពពេទ្យ ។

ដារ៉ា ៖ ចុះការហូបចុកអី តើហូបតាមក្រុម?

ប៊ុយ ៖ បាទ តាមក្រុម ។

ដារ៉ា ៖ តាមមុខព្រួញមួយៗ?

ប៊ុយ ៖ បាទ! ឧទាហរណ៍ថាមួយកងតូចគេមានចុងភៅ គេដាំបាយខ្លះមួយមក ដល់ពេលនេះទៅតាមក្រុមគេបើកម្ហូបតាមក្រុម ។

ដារ៉ា ៖ មិនមែនហូបទូទៅ?

ប៊ុយ ៖ មិនមែនទូទៅរាប់ពាន់ទេ គឺមួយកន្លែងៗ ។

យ៉ាង ៖ ពូអាចស្មានបានទេ អ្នកដែលនៅការដ្ឋានត្រពាំងថ្ម តើមានចំនួនអ្នកធ្វើការប៉ុន្មាននាក់ដែរ?

ប៊ុយ ៖ អ្នកលើកទំនប់?

យ៉ាង ៖ បាទ ។

ប៊ុយ ៖ អូហ៍ ច្រើនណាស់ ។ នេះអ្នកធ្វើការមុនខ្ញុំ ។

ដារ៉ា ៖ ដែលធ្វើការតាំងពីដើម?

ប៊ុយ ៖ បាទ!

យ៉ាង ៖ ប្រហែលប៉ុន្មាននាក់ដែរ?

ប៊ុយ ៖ ជិតម៉ឺនហើយ សង្ស័យតែម៉ឺនលើសផង ។ ជិត១ម៉ឺន ។ មួយកងតំបន់២០០០នាក់ ។ នេះគាត់កងចល័តមុនខ្ញុំ នៅកងចល័តស្រុក នៅវ័យកណ្តាល នៅកុមារទៀត ។ ច្រើនណាស់ ខុសពីម៉ឺនតែបន្តិច បើមើលទៅឃើញតែមនុស្សហ្នឹង ។

ដារ៉ា ៖ ខ្មៅព្រិចហ្នឹង?

ប៊ុយ ៖ បាទ! ខ្មៅព្រិច ហើយស្មើនេះព្ញូសូរស្នូរចបហើយ ។ ងាប់ក៏ច្រើនណាស់ ។ បើខ្ញុំគិតទៅក្នុងមួយយប់ប្រហែល១៥នាក់យ៉ាងតិច ។

ហ្វារីណា ៖ដោយសារអីទើបស្លាប់?

ប៊ុយ ៖ រកកំហុសមិនមានទេ ។ ស្លាប់ដោយសារលើកទំនប់នោះមធ្យមទេ គឺស្លាប់ដោយសារយកទៅវាយចោល ក្នុង១យប់យ៉ាងតិច១៥នាក់?

ដារ៉ា ៖ តើពេលដែលគេយកទៅហ្នឹងឲ្យដឹងទេ?

ប៊ុយ ៖ អ្នកធ្វើការនៅក្បែរៗគ្នាដឹងទេ ប៉ុន្តែដឹងតែពេលគេមក យក ឧទាហរណ៍ថា ប្អូនឯងប្រាប់ថាគេផ្លាស់ឲ្យទៅនៅកងខាងនោះ ប្អូនឯងឆ្លើយថា ចាំព្រឹក គេអត់ព្រមទេ គេឲ្យយើងទៅទាំងយប់ ។ គេសួររកខោអាវ គ្រាន់តែចេញទៅផុតពីរោងគេចាប់ភ្លាម ។

ដារី ៖ ប៉ុន្តែអ្នកដែលមកយកហ្នឹងស្លៀកពាក់ជាស៊ីវិលឬជាទាហាន?

ប៊ុយ ៖ បើនិយាយទៅឯកសណ្ឋានរបស់គេគឺអាវខ្មៅខោខ្មៅ និងកាំភ្លើង ។ នោះជាឯកសណ្ឋានយោធារបស់គេ ។ ប៉ុន្តែចល័តយើងក៏មានឯកសណ្ឋានអាវខ្មៅខោខ្មៅដែរ តែតារ៉ុង ប៉ុន្តែអត់មានមួកទើបដូចគេ ហើយមានកាំភ្លើង យើងអត់មានទេ ។

ដារី ៖ ចុះអ្នកហ្នឹងភាគច្រើនគេយកទៅសម្លាប់នៅឯណាវិញ?

ប៊ុយ ៖ ខាងត្បូងនេះហើយ ខាងត្បូងអាងយើង ដែលមានដើមពោធិ៍មួយប្រសិនបើយើងមើលពីស្ពាន ទៅឃើញដើមពោធិ៍១ វាលនោះសុទ្ធតែជាកន្លែងកប់ខ្មោច ។

យាន ៖ គេហៅកន្លែងអី?

ប៊ុយ ៖ គេហៅវាលតាគុយ ។

យាន ៖ តាគុយ?

ប៊ុយ ៖ បាទ! ហើយនៅភ្លឺអាងគេកប់នៅភ្លឺអាង ។

យាន ៖ តើពូអាចដឹងបានទេថាតើមានមនុស្សប្រហែលប៉ុន្មានដែរដែលគេបញ្ជូនទៅតាគុយ?

**ខាងបី**

ប៊ុយ ៖ កាលដែលវៀតណាមចូលមក កន្លែងនោះមានក្លិនអាសោធ ជួនកាលកប់ទៅមិនជិត វាឡើយ ខ្លាំងពេកវាគ្រាន់តែកាយដីបន្តិចកប់ទៅ ខ្លះនៅកណ្តាលវាល មានឆ្កែមានអីស៊ីទៅនៅសល់ឆ្អឹង ។ បើនិយាយពីក្នុងតំបន់ហ្នឹងវិញបែបចូលពាន់នាក់ហើយ ។

ដារ៉ា ៖កាលដែលមួយពេលដែលពូធ្វើនៅទំនប់ត្រពាំងថ្ម តើពូមានដឹងថាអ្នកណាជាអ្នកគ្រប់គ្រងនៅក្នុងតំបន់ហ្នឹងដែលមើលកន្លែងទំនប់ហ្នឹង?

ប៊ុយ ៖ ដូចខ្ញុំថា ភូមិភាគនិរតីគឺយន់ ជាអ្នកបន្តវេនពីតាវ៉ាល់ ។ តាវ៉ាល់ហ្នឹងគាត់ជាប្រធានតំបន់ ជាប្រធានតំបន់គ្រប់គ្រង...មេចល័ត ។ គាត់ត្រូវដកពីយោធាមកផ្ទាល់ ជាមេបញ្ជាការទំនប់នៅត្រពាំងថ្ម ដល់យកតាវ៉ាល់ហ្នឹងទៅសម្លាប់ទៅ ទើបយកយន់ឡើងគ្រប់គ្រង ។

យាន ៖អ្នកមកពីខាងនិរតី?

ប៊ុយ ៖ បាទ! មកពីនិរតី ។

ដារ៉ា ៖ ចុះក្នុងកងមួយៗ បើសិនជាប្រធានកងប្រធានកងតូចកងធំវរៈអី គេរាយការណ៍បន្តទៅស្រុក ទៅតំបន់អីពូ?

ប៊ុយ ៖ បាទ! ឧទាហរណ៍ថា ក្នុងថ្ងៃនេះមានកម្លាំងយើងកម្មករនៅក្នុងតំបន់យើង ល្ងាចឡើងចាប់ផ្តើមរាយការណ៍ហើយ ។ មេក្រុមរាយការណ៍មកកងតូច ហើយកងតូចរាយមកកងធំ កងធំរាយទៅវរៈ ហើយវរៈរាយទៅតំបន់ ។

ដារ៉ា ៖ នៅក្នុងពេលលើកជាអាងអីចឹង ពូធ្លាប់ឃើញមានថ្នាក់ដឹកនាំអីជាមេធំៗលើសពីតំបន់មកមើល មកសួរនាំឬមកទស្សនកិច្ចអីនៅកន្លែងហ្នឹងទេ?

ប៊ុយ ៖ បាទ! មានមិនមែនតែក្នុងប្រទេសទេ មានតាំងពីក្រៅប្រទេសទៀត ។ ហើយក្នុងនោះមួយឆ្នាំគេធ្វើមេទិញមុន និយាយទៅថា ថ្ងៃ...វាជួបនឹងយើងចូលឆ្នាំផង សរុបទៅ៣ថ្ងៃមុន កាលនោះ

គេហៅថា១៧មេសា ដូច្នេះចូលឆ្នាំយើងប៉ះចំថ្ងៃ១៤ ១៣-១៤-១៥ ។ ដូច្នេះគេយកត្រឹមថ្ងៃ១៥-១៦-១៧ បូកសរុបថ្ងៃជ័យជម្នះនិងថ្ងៃចូលឆ្នាំដូច្នេះទាំងបីនេះគេធ្វើអន្តមេទិញ ។

ដារ៉ា ៖ នៅហ្នឹងហ្មង?

ប៊ុយ ៖ បាទ! គេធ្វើនៅអាង ដោយមានសិល្បៈតន្ត្រីករ ច្រៀងរាំ ប៉ុន្តែច្រៀងរាំគេក្នុងនាមគេអាវុធយុទ្ធភណ្ឌកំប្លែណា ទៅចាប់អាយ៉ងឃួន អាយ៉ងលន់នល់ គេច្រៀងបែបហ្នឹងឯង ។

ដារ៉ា ៖គេសម្តែងសិល្បៈ?

ប៊ុយ ៖ បាទ! គេសម្តែងសិល្បៈឲ្យប្រជាជនមើល ។

ដារ៉ា ៖ មួយឆ្នាំម្តង ។

ប៊ុយ ៖ បាទ! មួយឆ្នាំម្តង ដោយក្នុងនោះមានពួកវិស្វករចិនចុះមកម្តង កាលហ្នឹងគេលេងសិល្បៈដែរនិងកុន ហើយកុននោះគេហៅកុនតាចាយ ។

ដារ៉ា ៖ដូចធ្លាប់ឮឈ្មោះដែរ តាចាយ ។

ប៊ុយ ៖ មិនមែនតែស្រុកខ្មែរទេ ទិដ្ឋភាពខ្សែភាពយន្តនោះគឺនៅស្រុកចិន គេចង់បង្ហាញយើងឲ្យឃើញឲ្យយើងធ្វើដូចគេ គ្រាន់តែនៅលើភ្នំគេអាចធ្វើប្រព័ន្ធភ្លឺស្រែខ្វាត់ខ្វែងបង្កើតទៅជាស្រូវបានណាដោយគេមិនបានពឹងផ្អែកលើភ្លៀងផ្គរទឹកជំនន់ណា ដោយគេយកទឹកភ្លៀងមក ហើយគេកាយថ្ម ។

ដារ៉ា ៖គេឲ្យអ្នកលើកទំនប់ហ្នឹងមើល?

ប៊ុយ ៖ បាទ! មើលគេឲ្យយើងអភិវឌ្ឍន៍តាមគេ ចិនគេមកសិក្សាផ្ទាល់ ។

យាង ៖ ពូសុំសួរត្រឡប់បន្តិច ពូថានៅក្នុងការដ្ឋានសាងសង់ហ្នឹងមានមនុស្សត្រូវគេបញ្ជូនទៅសម្លាប់ឬទៅកន្លែងសហករណ៍ផ្សេង ប៉ុន្តែបាត់ខ្លួន តើពូគិតថាគេបញ្ជូនទៅសម្លាប់ តើពូគិតថាអ្នកដែលគេចាប់បញ្ជូនទៅកន្លែងផ្សេង គាត់ជាប់និន្នាការឬធ្វើការអត់គ្រប់ផែនការឬយ៉ាងម៉េចទើបគេបញ្ជូនទៅ?

ប៊ុយ ៖ វាមានច្រើនដូនកាលវាស្រាវជ្រាវទៅដឹងថាទាហាន វាក៏សម្លាប់ ដូនកាលវាស្រាវជ្រាវទៅឃើញថា ពួកនិស្សិតបញ្ញាវន្តឲ្យតែអ្នកចេះជ្រៅជ្រះក៏វាសម្លាប់ ទី៣ធ្វើការមិនពេញដៃជើងហៅថាទារុណស្មុក់ នោះក៏គេយកទៅសម្លាប់ ។ ទី៤បើវាស្អប់បុគ្គលណាមួយហើយគឺត្រូវបាត់ខ្លួនហើយបើវាមិនពេញចិត្ត គោលបំណងវាមិនពេញចិត្តនឹងបុគ្គលនោះ ហ្នឹងក៏ត្រូវបាត់ខ្លួនដែរ ។ វាអត់រើសមុខរើសមាត់ទេ ប៉ុន្តែប្រសិនបើឈ្មោះកចាប់ឈ្មោះក ប៉ុន្តែតាមការពិតកំហុសរបស់ខ ទេ ។ គេថាខនេះទាហានប៉ុន្តែចាប់ប៉ះក បើចាប់ហើយអត់លែងមកវិញទេ គឺត្រូវតែកម្ទេច

ចោល ហើយខនោះមិនរួចខ្លួនទេ គឺត្រូវយកទៅទៀត អត់មានថាអូហ៍ភាន់ច្រលំទេ ឲ្យតែចាប់ហើយគឺហើយ ។

ដារ៉ា ៖ អ៊ីចឹងអ្នកដែលនៅជាប់ខាងគ្នាដឹងដែរ ដឹងថាគេមានការយកទៅសម្លាប់ យកទៅអី?

ប៊ុយ ៖ ដឹង ប៉ុន្តែមិនហ៊ាននិយាយទេ ប្រសិនបើហ៊ាននិយាយ...ដឹងតែយកទៅទាំងយប់ហើយគឺយកទៅសម្លាប់ហើយ ។

ដារ៉ា ៖ គឺអ្នកនៅទំនប់ដឹងអ៊ីចឹងហ្នង?

ប៊ុយ ៖ បាទ! យើងកំពុងនៅជុំគ្នា គ្រាន់តែក្រវាសខ្លួនគឺទៅហើយ ដូច្នេះអ្នកដែលនៅអែបយើងគឺដេកមិនបានទេ គឺវារន្ធត់ក្នុងខ្លួន ។

យាង ៖ ពូគិតថាគោលនយោបាយដែលគេយកទៅជាការសម្រេចរបស់អ្នកនៅកន្លែងការដ្ឋានហ្នឹងឬមានការសម្រេចរបស់អ្នកមកពីលើមកឬយ៉ាងម៉េច តើពូអាចដឹងបានទេ?

ប៊ុយ ៖ មិនដឹងទេរឿងនោះ ស្រាប់តែពេលដេកគេយកទៅបណ្តោយ ដូចថាវាមានកងឈ្លបសម្ងាត់របស់វា វាដើរស្រាវជ្រាវរកតាំងពីទាហាន តាំងពីទាហានសម័យសាធារណរដ្ឋខ្មែរ ឲ្យតែជាប់និន្នាការ ។

យាង ៖ ប៉ុន្តែឈ្លបសម្ងាត់គឺជាឈ្លបរបស់អ្នកនៅក្នុងតំបន់ហ្នឹងឬមជ្ឈិមឬយ៉ាងម៉េច?

ប៊ុយ ៖ តំបន់ ។ គេទម្លាក់ចុះមក ។

យាង ៖ តំបន់?

ប៊ុយ ៖ បាទ! តំបន់គេទម្លាក់ចុះមក ។

យាង ៖ ពូនៅក្នុងអង្គភាពហ្នឹង ដូចថាមនុស្សរាប់ហូតដល់ចង់ម៉ឺន ភាគច្រើនពូគិតថាមនុស្សទាំងអស់ហ្នឹងមកពីខាងណាដែរ ។ មានអ្នកជម្លៀសមកពីភ្នំពេញ ១៧មេសាដែរ?

ប៊ុយ ៖ និយាយទៅវាមានចម្រុះមានតាំងពីអ្នកមកពីភ្នំពេញ តាំងពីមូលដ្ឋាន មូលដ្ឋាននេះមាន៥ស្រុក មានភ្នំស្រុក ព្រះនេត្រព្រះ មង្គលបូរី សេរីសោភណ្ឌ ថ្មគោល សុទ្ធតែអ្នកមូលដ្ឋាន ដូចថាមានអ្នកមកពីភ្នំពេញផង វាចម្រុះជុំគ្នាហ្នឹងឯង បើនិយាយទៅ៦អង្គភាព ព្រោះស្រុកដឹងថា៥ហើយ ចល័តតំបន់១ទៀត វាត្រូវជា៦អង្គភាព ។

យាង ៖ ចុះការធ្វើការងារ ដូចថាអ្នក១៧មេសានិងមូលដ្ឋានមកពី៥ស្រុកអ៊ីចឹង គេចម្រុះគ្នាឬបែងចែកគ្នា?

ប៊ុយ ៖ គេដាក់ចម្រុះគ្នា ។ វាមាន បើសិនជាគេអ្នករំដោះចាស់ គេក្តាប់យើង ។ ហើយថ្នាក់ដឹកនាំធំៗដូចជាប្រធានវរៈនិងចល័តតំបន់ មេតំបន់ នោះហៅថាកងចល័តចាស់ អ្នករំដោះចាស់ ដូចជា

អ្នក១៧មេសាគ្រាន់តែបាន១កងធំ កងតូច ដល់ណែកងពលមកពីទីក្រុងភ្នំពេញនោះបានត្រឹមជាកូនក្រុម ហើយ១៧មេសាខ្លះក៏ធ្វើកូនក្រុម ។ គេអត់មានថា បែកដាច់ដោយឡែកពីគ្នាទេថា អ្នក១៧មេសាធ្វើមួយឡែក ហើយអ្នករំដោះចាស់មួយឡែក អ្នកមកពីភ្នំពេញមួយឡែកអីអត់មានទេ គេប្រឡាច់បញ្ចូលគ្នាទាំងអស់ ។

ហ៊ុរីណា :ចុះចំពោះអ្នកដែលត្រូវរកឃើញថាជាទាហានដែលគេរកឃើញហើយយកទៅបាត់ តើសម្រាប់ស្ត្រីដែលជាប្រពន្ធអ្នកដែលគេយកទៅ តើគេយកទៅទាំងអស់គ្នាឬយកទៅផ្សេង?

ប៊ុយ : នេះខ្ញុំនិយាយតែចល័តទេ ព្រោះនៅក្នុងមូលដ្ឋាននេះ ប្រសិនបើប្តីធ្វើទាហាននៅក្នុងរបបលន់នល់ ដូចបុណ្យសក្តិ សក្តិ១ស័ក្ត២ ទាំងប្រពន្ធទាំងកូនប្រមូលគ្នាមក គឺមានឡានមានត្រាក់ទ័រប្រមូលយកទៅ ប៉ុន្តែដោយឡែកពួកខ្ញុំកងចល័តគឺអត់មានយុវជនទេ មានតែយុវជននិងនារីដូចថាណែទាហានទៅ យកតែប្រពន្ធមួយទៅ បើនៅភូមិមានប្តីប្រពន្ធនិងកូន បើសិនជាកូនចល័តនៅឯណា សួរឪពុកម្តាយពីភូមិទៅ រួចហើយគេតាមទៅយកយើងនៅកន្លែងធ្វើការងារ ។

ហ៊ុរីណា : ចុះនៅមូលដ្ឋានពូមានឮថាមានការរំលោភស្ត្រីកើតឡើងទេ?

ប៊ុយ : រំលោភសិទ្ធិឬ?

យាង :រំលោភផ្លូវភេទ លើរូបរាងកាយ?

ប៊ុយ : មាន មិនថាតែនៅក្នុងភូមិឬនៅចល័តទេវាមាន ដូច្នេះគេចាប់ទាំងពីរនាក់យកទៅ គេហៅថាចូលកងករណី ។

ដារី : កងករណី?

ប៊ុយ : បាទ! សម័យនោះគេហៅថាកងករណី បើនិយាយទៅ គេថាជាទីកន្លែងកសាង ជាកន្លែងអប់រំណែនាំ ។ កន្លែងនោះជាកន្លែងតឹងតែបំផុតព្រោះយើង យើងប្រព្រឹត្តអំពើខុសសីលធម៌ គេយកទៅ នេះបើសិនជាខ្លះគេយកទៅកងករណី ខ្លះគេមិនបានយកទៅ គេបញ្ជូនទៅកន្លែងព្រះធរណីតែម្តង យើងនិយាយដោយខ្លី គឺសម្លាប់ចោល ។

ហ៊ុរីណា :តើមានដែលមានករណីខ្លះគេយកមកធ្វើជាគំរូដល់អ្នកផ្សេងទៀត ឧបមាថាគេចាប់បានអ្នកដែលខុសសីលធម៌ ហើយគេយកមកធ្វើបាបដើម្បីបង្ហាញអ្នកស្រុកភូមិផ្សេងទៀត មានដែរទេ?

ប៊ុយ : អត់ទេ គេសម្លាប់ចោលហើយ បើនិយាយទៅ គេមិនដែលប្រជុំធ្វើជាមេទិញអីទេ នេះគំរូអាក្រក់ បានខុសសីលធម៌ យុវជន ឬយ៉ាងម៉េចទេ គេមិនធ្វើអីចឹងទេ គឺបាត់ខ្លួនតែម្តង ។

ចន្ថា :បើកន្លែងខ្ញុំគេរើសយកស្អាតៗ គេរើសយកស្អាតៗ គេយកទៅកន្លែងផ្ទះមួយជិតភ្នំ អាធំជាងគេ កាលហ្នឹងអាមេបញ្ជាការធំជាងគេ ឈ្មោះ តាឡេង នៅស្វាយ ។ កាលហ្នឹងគេរើស

អន្តភាពខ្ញុំផ្សេងគ្នា អន្តភាពខ្លះគេធ្វើបាប អន្តភាពខ្លះវាអត់ធ្វើបាបទេ ពុករលួយចុះ ។ កាលហ្នឹង មានម្នាក់ឈ្មោះដូចខ្ញុំអីចេះឯង វាឃើញខ្ញុំនៅកន្លែងនេសាទ វាចាប់អូសខ្ញុំព្រឹប ហើយយំឱបប្រាប់ខ្ញុំថា «វាធ្វើបាបខ្ញុំ វាឲ្យនិរសារវាចាប់ខ្ញុំបាន ឲ្យវាឡើងលើគ្រែ ។ ដល់វារំលោភយើងរួច វាយកយុវជនមករៀបការជាមួយវា វាសម្លាប់ថាវាធំនោះ ដល់ពេលនេះឡើងវាឲ្យយកប្តី» ។ គ្នាមិនស្រលាញ់មិនអីទេ ប៉ុន្តែគេបង្ខំ ហើយសព្វថ្ងៃនេះនៅសហរដ្ឋនេះ ។

យាង ៖ តើគាត់ឈ្មោះអី?

ចន្ថា ៖ ឈ្មោះចន្ថា ។

ហ្វារីណា ៖ គាត់ជាអ្នក១៧មេសាឬមូលដ្ឋាន?

ចន្ថា ៖ មូលដ្ឋាននេះឯង ។ វាយំប្រាប់ វាថាធ្វើបាបខ្ញុំណាស់ ខ្ញុំឲ្យតែឮសន្ធឹកម៉ូតូវាញ័រអស់ភ័យណាស់ ។

ដាវី ៖ ក្រៅពីករណីមីងដែលនៅអាមេរិកហ្នឹង តើមានអ្នកផ្សេងទៀតទេ?

ចន្ថា ៖ អត់មានទេ មានតែវា ។ ខ្ញុំមិនដឹងដែរ ទើបតែឮវាប្រាប់ខ្ញុំ ។

ប៊ុយ ៖ ព្រោះវាស្អាត ។

ចន្ថា ៖ កាលហ្នឹងសម័យប៉ុលពតដូចគ្នាប៉ុន្តែអន្តភាពផ្សេងគ្នា ដល់ឃើញខ្ញុំទៅ អ្នកស្រុកភូមិដូចគ្នាឃើញអីចឹងវាចាប់អូសខ្ញុំព្រឹប វាយំ ខ្ញុំក៏យំ វាក៏យំ ធ្វើយ៉ាងម៉េចដកវាពីកន្លែងនេះបាន វាឲ្យខ្ញុំដកវាមកនៅកន្លែងខ្ញុំ ។ ដកយ៉ាងម៉េចបានបើគ្នា (អ្នករំលោភ) ជាអ្នកធំ បើដកគេសម្លាប់ឯងទៀត ។ វាចេះតែតស៊ូជាមួយគេវៀតណាមចូលមកទើបរួចខ្លួន ។ កាលហ្នឹងប្តីវាមិនស្រលាញ់ចេះតែចាប់បង្ខំឲ្យគ្នារៀបការ ។ ឥឡូវគ្នាទៅនៅសហរដ្ឋ ។

ហ្វារីណា ៖អំពើនោះជាអំពើខុសសីលធម៌ នៅក្នុងសម័យខ្មែរក្រហម ដល់ពេលមានការចាប់រំលោភអីអីចឹងតើគេអត់មានសើរើឬសួរនាំអីទេ?

ចន្ថា ៖ទេ កាលហ្នឹងមេគេយកទៅសម្លាប់ចោលមួយលើកៗអស់រលីង ។

ប៊ុយ ៖ អ្នកដែលរំលោភហ្នឹងត្រូវគេយកទៅសម្លាប់ចោលហើយ ព្រោះវាធំដែរ ។ ទម្រាំតែនិរតីចូលមកគេយកទៅសម្លាប់ចោល ។

ហ្វារីណា ៖គាត់ឈ្មោះអី?

ចន្ថា ៖ឈ្មោះ តាឡេង ។

ដាវី ៖ គាត់ស្លាប់ហើយ?

ចន្ថា ៖ស្លាប់ហើយ ។

ដារ៉ា ៖ ស្ងាប់កាលជំនាន់ណា?

ចន្ទា ៖ ស្ងាប់ពេលជំនាន់នោះ កាលដែលនិរតីចូលមក ។

ដារ៉ា ៖ កាលដែលគេយកគាត់ទៅសម្លាប់ដោយសារមូលហេតុដែលគាត់រំលោភមីងហ្នឹងឬយ៉ាងម៉េច?

ចន្ទា ៖ អត់ទេ មិនមែនដោយសាររំលោភទេ ។ គេថាក្បត់ ។

ដារ៉ា ៖ ត្រកមកខាងពូវិញម្តង ពេលដែលលើកទំនប់ច្រើនអីចឹង ពេលដែលធ្វើការតើមានការបង្ខិតបង្ខំក្នុងពេលធ្វើការងារទេ ឧទាហរណ៍ថាពេលដែលយើងធ្វើស្ទក់អីត្រូវទាត់ៗ ត្រូវវាយៗអីយ៉ាងម៉េចមានទេ មានសកម្មភាពអីចឹងខ្លះទេ?

ប៊ុយ ៖ មានដែរ ។ ប៉ុន្តែមិនដល់...គ្រាន់តែថា គេហាមថាកុំលួច យើងទៅលួចអីណា នោះមេកងហាមប្រាម រឿងដែលមេកងយកទៅវាយចោលអត់មានទេ មានតែគេធំៗ រឿងកងតូចកងធំគ្រាន់តែអប់រំប្រាប់ថាកុំទៅលួចប្រយ័តបាត់ខ្លួន ។ និយាយទៅថាក្រពះទាមទារខ្លាំងពេក ។

ដារ៉ា ៖មានពេលឯណាទៅលួចកើតបើការងារធ្វើសឹងតែរកពេលសម្រាកអត់បាន?

ប៊ុយ ៖ ទេ ធ្វើពេលយប់ ប៉ុន្តែថ្ងៃឡើងដេក សម្រាកម៉ោងល្ងាចអីយើងនៅ ដល់ពេលនេះទៅអាណាក្តៅបែកញើសដេកមិនបាន ដូចថា១២ម៉ោងយើងមិនមែនដេកបាន១២ម៉ោងទេ ជួនកាលម៉ោង២អីយើងមកផ្ទួតទឹកអី ដើរមកតាមសហករណ៍តាមព្រៃតាមអី វាមានដែរ ។

ដារ៉ា ៖ បាទ!

យាង ៖ខ្ញុំសុំសួរបន្តិច ពូនិយាយថា ឈ្មោះយន់ ជាអ្នកគ្រប់គ្រងនៅហ្នឹង?

ប៊ុយ ៖ បាទ!

យាង ៖ តើលោកពូអាចរៀបរាប់អ្នកធ្វើការជុំវិញគាត់ ពីលើគាត់អី ឬក្រោមគាត់ ពូអាចចាំអ្នកណាខ្លះជួយរៀបរាប់ប្រាប់ខ្ញុំ ។

ប៊ុយ ៖ ក្នុងនេះបើនិយាយពីអ្នកកាន់កាប់ខ្ញុំគឺនិរតីឈ្មោះ តាចេង តានិន ។

យាង ៖គាត់ធ្វើអីដែរលោកពូ?

ប៊ុយ ៖ គាត់និយាយទៅដូចថា... ។

យាង ៖ទទួលបន្ទុកអី?

ប៊ុយ ៖ ប្រធានវរៈយើងមានហើយ ប៉ុន្តែគេសង្កេតតាមដានយើង ជាគិញរបស់គេ ។

យាង ៖គិញរបស់យន់?

ប៊ុយ ៖ បាទ តាមដានវរៈខ្ញុំមាន២នាក់ ប៉ុន្តែមកពីនិរតី ។ នៅតែថ្ងៃយកប្រធានវរៈទៅគេកាន់អំណាចដល់ទីបំផុត មិនបានសម្លាប់នៅនេះ ឈ្មោះតានិននោះបាន...យន់នោះបានដកកម្លាំងពួកខ្ញុំវរៈខ្ញុំ

យកទៅចម្ការកប្បាសដល់នេះបានដកប្រធានវរៈខ្ញុំថាឲ្យទៅប្រជុំ ទៅប្រជុំបាត់បណ្ដោយ ហើយ តាប៉ិ និន កាន់កាប់បណ្ដោយ ។

យាន ៖អ៊ីចឹងប្រធានវរៈពូមុន និន ឈ្មោះអី?

ប៉ុយ ៖ ឈ្មោះ ប៊ូ ហើយប៊ូនោះជាអ្នកមកពីភូមិភាគពាយ័ព្យគេជាអ្នករំដោះចាស់ ។

យាន ៖ ចុះក្រោមហ្នឹងទៀតមានដូចជាថ្នាក់ស្រុកថ្នាក់ឃុំអីមានចាំទេ?

ប៉ុយ ៖ ទេនេះខ្ញុំនិយាយពីចល័តរបស់ខ្ញុំ គឺចល័តតំបន់ណា៎ ។

យាន ៖ អូហ៎ ដូរចល័ត?

ប៉ុយ ៖ បាទ! មាននៅភ្នំស្រុក ។

ហ្សារីណា ៖ ទាក់ទងនឹងយាយថែម តើពូបានដឹងថាកម្លាំងគាត់ប៉ុន្មាននាក់ដែរ ដែលយកមកធ្វើការនៅ ខាងទំនប់?

ប៉ុយ ៖ អត់ទេ យាយថែមនេះអត់បានធ្វើនៅទំនប់ទេ បើនិយាយទៅថា...នែ យើងនិយាយជាសមញ្ញ គាត់នៅខាងស៊ីវិល នៅស្រុកនៅភូមិឯណោះ ដែលនៅឯណោះជាចល័តតំបន់ ដល់ពេល៧៩ ពេលដែលវៀតណាមវាយរំដោះមក យាយថែម ក៏ដកខ្លួនមកខាងនេះ ក៏រួមកម្លាំងជាមួយយន់ នាំគ្នាគេចខ្លួនទៅក្នុងព្រៃ ។ ដល់នេះមកទើបនិយាយថាយាយថែមកាចណាស់នៅភ្នំលាភ ។ រឿង ខ្ញុំឲ្យទៅសំណេះសំណាលជួប ហើយកម្លាំងមានប៉ុន្មានៗទេ ។ ដាច់ដោយឡែកពីគ្នា ។

ដារី ៖ ចុះថាយាយថែមកាចនោះ តើកាចរបៀបម៉េច?

ប៉ុយ ៖ រឿងកាចនោះ ដែលបងប្អូនថាកាច គឺកាចដោយយកបងប្អូនទៅសម្លាប់ចោល ដូច្នេះចេះតែពូ តៗគ្នា ឲ្យតែយកទៅសម្លាប់គឺកាចហើយ មិនមែនកាចដូចសម្ដីទេ គ្រាន់តែគាត់បញ្ជាអ្នកដែល នៅក្រោមឱវាទរបស់គាត់ តាមសហករណ៍គេរាយការណ៍មក ។

ដារី ៖ តើសព្វថ្ងៃនេះមានបងប្អូនឬបងប្អូនណាដែលធ្លាប់ឃើញយាយថែមបញ្ជាគេយកមកមនុស្សទៅ សម្លាប់ដែរ?

ប៉ុយ ៖ បើនិយាយទៅ គេយោធាសព្វថ្ងៃគេបែកគ្នាទៅណាទៅណែអស់ហើយ កាលហ្នឹងនៅជុំគ្នា ចេះ តែនិយាយប្រាប់ថាពួកយាយថែមកាចកំពូលមនុស្សស្រី កាចក្នុងការដូចថាម៉ឹងម៉ាត់នឹងការងារ អត់មានអនុគ្រោះពេលណាដែលខុសឆ្គងស្អី ដូចថាខុសបន្តិចបន្តួចយើងអធ្យាស្រ័យគ្នា បើថា ទៅខាងនេះទៅ បើមិនទៅដាក់ដូង ។ បើថាឲ្យទៅខាងណោះហើយយើងអត់ទៅទេ មុខជាបាញ់ ចោល ឬត្រូវសម្លាប់ ។ នេះខ្ញុំគ្រាន់តែជម្រាបអ៊ីចឹង ។

ដារី ៖ ចា៎ អ៊ីចឹងនៅក្នុងភូមិនេះអត់មានអ្នកណាមានសាច់ញាតិបាត់បង់ដោយសារយាយថែមទេ?

ប៊ុយ ៖ អត់ទេ ។ ព្រោះយាយថែមនៅខាងព្រះនេត្រព្រះ ។ ពេលដែលវៀតណាមចូលតាមផ្លូវជាតិលេខ៦គាត់គេចមកនៅនេះ ។

ដារ៉ា ៖ នៅនេះ នៅឯណាវិញ?

ប៊ុយ ៖ នៅក្នុងវត្ត ។ កាលណោះពួកខ្ញុំត្រឡប់ទៅផ្លូវជាតិលេខ៦ហើយណា៎ ។ នេះជាទឹកដីរបស់គេ គេគ្រប់គ្រងអស់ហើយ ។

ហ្វារីណា ៖ពូអម្បាញ់មិញមានប្រសាសន៍ថា ជនជាតិវៀតណាម ជនជាតិចិន ពេលដែលគេរកឃើញត្រូវយកទៅសម្លាប់ ក្រៅពីហ្នឹងអាចមានជនជាតិផ្សេងទៀតដូចជាចាមអី តើពូមានដែលឮទេថាមាននៅខាងទំនប់ហ្នឹង?

ប៊ុយ ៖ ទេ ជនជាតិចាម ដូចជាមិនឮ បើខ្ញុំងបំផុតមានតែចិននិងយួន ឲ្យតែលេចឮគឺសម្លាប់ចោល ហើយចាមមានខ្លះដែរ ក្នុងតួចខ្ញុំ ប៉ុន្តែមិនដែលឃើញសម្លាប់ទេ វាដឹងថាចាម ប៉ុន្តែពេលដែលមានសាច់ជ្រូក ចាមអត់ហូបទេដាក់មកមិនហូប ក៏វាមិនធ្វើអីដែរ អាណោះទៅរកអំបិលរកអីប្រជាជនទៅរកអំបិលអីតាមដំណើរ ប៉ុន្តែរឿងសាច់ជ្រូកគេថាមិនរ៉ាក់ (ហូប) ប៉ុន្តែវាអត់ធ្វើអីទេ បើនិយាយពីចិននិងយួនមិនត្រូវគ្នាសោះ ដឹងតែបាត់ខ្លួន ។

ហ្វារីណា ៖តើពូមានប្រសាសន៍ហ្នឹងនៅមូលដ្ឋានឬនៅកន្លែងទំនប់ពូ ដែលថាអត់សូវមានជនជាតិចាមឬមិនសូវមានការបង្ខំ (ឲ្យហូបសាច់ជ្រូក)?

ប៊ុយ ៖ ហ្នឹងនៅចល័តរបស់ខ្ញុំ ចល័តតំបន់ បើនិយាយពីរឿងមូលដ្ឋាន ខ្ញុំសុំទោសខ្ញុំអត់ដឹងទេ ។

ដារ៉ា ៖ បាទ!

ប៊ុយ ៖ ព្រោះខ្ញុំនៅចល័តប៉ុន្មានខែមិនហ៊ានចូលមូលដ្ឋានទេ ខ្ញុំខ្លាចលោហ៍បាត់ខ្លួន ខ្ញុំនៅបានស្រួលសិន គេនៅបានស្រួលសិនទើបខ្ញុំចូលទៅបណ្តោយ ។

ដារ៉ា ៖ ពូចុងក្រោយនេះ ខ្ញុំចង់សួរពីរឿងវាលតាគុយ កន្លែងវាលតាគុយដែលពូបានរៀបរាប់ថាជាកន្លែងសម្លាប់ហ្នឹង តើវានៅឆ្ងាយពីកន្លែងការដ្ឋានលើកទំនប់ហ្នឹងដែរ ឬយ៉ាងម៉េច?

ប៊ុយ ៖ មិនឆ្ងាយទេ ព្រោះទំនប់ទៅលិចអីចេះ គេជីកអីចេះ ហើយបើសិនជាក្លិនអាចមកដល់ ។

ដារ៉ា ៖ បើសិនជាក្លិនអាចមកដល់?

ប៊ុយ ៖ បាទ! ខ្យល់បក់មកវ៉ូៗ អាចមានក្លិន ហើយនិងតាមបណ្តោយព្រែក ព្រែកនៅជិតហ្នឹងក៏មានដែរ ហើយគេ (ខ្មែរក្រហម) មិនមែនសម្លាប់តែនៅវាលតាគុយទេ នៅក្នុងតំបន់ក្នុងអាងនោះក៏សម្លាប់ដែរ ហើយនៅក្នុងភ្នំអាងក៏សម្លាប់ដែរ ។

យាង ៖ អូហ៍ នៅការដ្ឋានហ្នឹងហ្នង?

ប៊ុយ ៖ បាទ! ព្រោះយើងអ្នកដែលសម្លាប់អ្នកដែលធ្វើនោះក៏មិនដឹងដែរគ្រាន់វាព្រុស ទៅក៏លុបបាត់ មានអ្នកលើកមកចាក់ពីលើ ។

ដារ៉ា ៖ អូហ៍ ពេលដែលកំពុងចាក់ដី?

ប៊ុយ ៖ បាទ! កន្លែងណាងងឹតដាក់កុសទៅៗ យើងចល័តចាក់ដីលុបពីលើអត់ដឹងថាខ្មោចទេ ។

ដារ៉ា ៖ អូហ៍ មានអីចឹងទៀត?

ប៊ុយ ៖ បាទ! ច្រើនណាស់នៅទំនប់នេះស្លាប់ហ្នឹង ។

ដារ៉ា ៖ ហើយកន្លែងវាលតាគុយនេះមាននៅសេសសល់អីដែលជាក្រណាត់ ជាឆ្អឹងខ្លះទេ?

ប៊ុយ ៖ មិននៅទេ វប៉ាត់វប៉ាយព្រោះកន្លែងភ្ជួរស្រែធ្វើស្រែធ្វើអី ។

ដារ៉ា ៖ ជាកន្លែងស្រែ ឥឡូវគេធ្វើស្រែនៅលើហ្នឹងហើយ?

ប៊ុយ ៖ បាទ! ធ្វើស្រែហើយ ។

ដារ៉ា ៖ចុះកាលដែលធ្វើស្រែ មានធ្លាប់ឮអ្នកដែលធ្វើស្រែហ្នឹងនិយាយថា ភ្ជួរទៅ ប៉ះចំឆ្អឹងប៉ះអីទេ?

ប៊ុយ ៖ មាន ។ នៅអែបភ្លឺ វារលួយអស់រលីង វារប៉ាត់រប៉ាយអស់រលីងហើយ ។ ដូច្នេះបើយើងនិយាយទៅជាភស្តុតាងអីរកមិនបានទេ ។ វាអស់រលីងហើយ ។

ដារ៉ា ៖ ប៉ុន្តែយ៉ាងហោចណាស់ យើងអាចដឹងពត៌មានពេលដែលអ្នកស្រុកអ្នកភូមិទៅធ្វើស្រែនៅហ្នឹង ធ្លាប់ភ្ជួរទៅប៉ះឆ្អឹងប៉ះអីចឹង តើធ្លាប់មានអីចឹងដែរឬទេ?

ប៊ុយ ៖ មាន ភ្ជួរទៅប៉ះ ប៉ះទៅ កាលហ្នឹងមិនបាននេះទេ កាលហ្នឹងយើងនៅតាមវត្តអារាមជំនាន់សាធារណរដ្ឋកម្ពុជា គេឲ្យយើងធ្វើស្តូក ដូចឆ្អឹងនិងក្បាលខ្មោចអីគេយកមកដាក់តាំងនឹងស្តូកហ្នឹង កន្លែងណាក៏ដោយ ឆ្អឹងហ្នឹងពីកន្លែងណាក៏ដោយនៅពេលដែលគេឃើញយើងចេះតែយកមកដាក់តាំង ។

ដារី ៖ប៉ុន្តែឆ្អឹងនៅកន្លែងវាលតាគុយហ្នឹងគេយកទៅដាក់នៅឯណាវិញ?

ប៊ុយ ៖ គេយកទៅដាក់នៅស្តូកនេះឯង ។

ដារី ៖ ស្តូកនៅឯណា?

ប៊ុយ ៖ នៅក្នុងវត្ត ។

ដារី ៖ វត្តណាទៅ?

ប៊ុយ ៖ វត្តត្រពាំងថ្ម ។ ប៉ុន្តែស្តូកហ្នឹងរប៉ាត់រប៉ាយអស់ហើយ គេបូជាអស់ហើយ គេបញ្ជូនចម្ងល់ឲ្យផុតពី...

ដារី ៖ ខុទ្ទិសកុសល

ប៊ុយ ៖ ជូនទៅចាប់បដិសន្ធិប៉ុន្តែបើឲ្យឃើញភស្តុតាងដូចយើងសព្វថ្ងៃនេះ ដូចជាទូលស្វែងអី មិនឃើញទេ ។

ដារ៉ា ៖ ចុងក្រោយចង់ទៅមើលកន្លែងទំនប់ហ្នឹងបន្តិចដែរពុ ។

ប៊ុយ ៖ ទៅវាល ទៅរកជាភស្តុតាងថាមានកប់អីអត់មានទេ ។

ដារ៉ា ៖អត់ទេ ខ្ញុំចង់ទៅមើលកន្លែងទំនប់ហ្នឹងហ្នង តើវានៅជារាងទំនប់ហ្នឹងហ្នង តើនៅទេ?

ប៊ុយ ៖ នៅ វាមានតែទំនប់អាងប៉ុន្តែកន្លែងកប់ខ្មោចអត់មាននេះទេ មានតែវាលស្រែអស់រលីង ។

ដារ៉ា ៖ ខ្ញុំគ្រាន់តែចង់ទៅមើលកន្លែងទំនប់ហ្នឹងទេ ថាតើទំនប់ហ្នឹងលើកទៅវារាងយ៉ាងម៉េច យើងឮតែថាទំនប់ត្រពាំងថ្ម ប៉ុន្តែខ្ញុំមិនដែលទៅមើលកន្លែងហ្នឹង អត់ដែលទៅជាន់កន្លែងហ្នឹងទេ អ៊ីចឹងខ្ញុំចង់ទៅមើលទំនប់ហ្នឹង ។

យាង ៖ពូខ្ញុំសុំសួរតែមួយសំណួរទៀតទេ អ្នកដែលនៅលើពីលើយន់ គាត់ឈ្មោះអីដែរ?

ប៊ុយ ៖ ខ្ញុំអត់ស្គាល់ទេ គ្រាន់តែឮថាគេកាន់តំបន់ហើយ ប៉ុន្តែខ្ញុំដឹងថា តាម៉ុកនៅប្រធានតំបន់ ។ ប៉ុន្តែភូមិភាគអ្នកណាទេ កាន់ខាងភូមិភាគ ។

ពេជ ៖ តាម៉ុក...ទេឈ្មោះអីទេ ។

ប៊ុយ ៖ តាម៉ុក ជាប្រធានតំបន់ ដល់មកកាន់ចល័តតំបន់នេះ តាប៊ុយន់ ។

ដារី ៖ចា៎! ប៉ុន្តែតំបន់នេះឈ្មោះតំបន់អី?

ប៊ុយ ៖ តំបន់៥ ។

ដារី ៖ ភូមិភាគប៉ុន្មាន?

ប៊ុយ ៖ ភូមិភាគពាយ័ព្យ ។

យាង ៖ពូខ្ញុំសុំសួរថាពូមានដែលឮដំណឹងពីការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ប៊ុយ ៖ ទេឮដែរ ឮថាកាត់ទោស១ អ្នកខ្លះថាសម្រេច ហើយខ្លះមិនទាន់សម្រេច ។

យាង ៖ តើពូឮតាមអីដែរ តាមកាសែតតាមវិទ្យុឬទូរទស្សន៍?

ប៊ុយ ៖ តាមវិទ្យុ ។

យាង ៖ តើពូយល់យ៉ាងម៉េចដែរ តើពូគាំទ្រឬយ៉ាងម៉េច?

ប៊ុយ ៖ ទេ បើនិយាយពីថា គំនិតខ្ញុំ ខ្ញុំអត់គាំទ្រទេ មានតែថ្កោលទោសថែម ព្រោះដោយសារគាត់ទើបខ្ញុំបែកបាក់ពីក្រុមគ្រួសារនិងបែកបាក់ឪពុកម្តាយស្លាប់ចោលអស់ ដូច្នេះការល្ងឹងជូរចត់របស់ខ្ញុំវាឆ្អែតណាស់ វាជិត៤ឆ្នាំ ហើយសូម្បីតែប្អូនខ្ញុំនៅតូច១ប៉ុណ្ណេះ ក៏ខ្ញុំមិនបានគ្រប់គ្រងដែរ ខ្ញុំ

ភ័យខ្លួនខ្ញុំដែលខ្ញុំជាប់និន្នាការ បើសិនជាខ្ញុំរស់នៅក្នុងភូមិគឺខ្ញុំត្រូវបាត់ខ្លួនហើយ ដូច្នេះបងប្អូនថាឪពុកម្ដាយស្លាប់ចោលហើយ ថាវាឆ្អែត ។

យាង : ចុះពូដូចថាដោយសារពូមានសាច់ញាតិបាត់បង់ ហើយឆ្អែតជាមួយរបបហ្នឹង តើពូគិតថាក្រោយពីការកាត់ទោសទៅ តើពូនឹងមានអារម្មណ៍ផ្សះផ្សារសាយក្នុងចិត្តទេ?

ប៊ុយ : រសាយ ព្រោះវាអស់ទៅហើយរសាយ ដូច្នេះគឺថា បើសិនជាកាត់ទោសខ្មែរក្រហមរួចអស់ហើយខ្ញុំមានចិត្តរំភើបរីករាយដោយមានថ្នាក់លើ អង្គការសហប្រជាជាតិថ្កោលទោសឲ្យ បើសិនជាខ្លួនខ្ញុំទៅកាត់ទោសខ្លួនឯងក៏មិនកើតដែរ ។

ដារ៉ា : បាទ!

ដារី : ចុះពូមានបងប្អូនទាំងអស់ប៉ុន្មាននាក់?

ប៊ុយ : ខ្ញុំមានបងប្អូនទាំងអស់៩នាក់ ហើយខ្ញុំជាកូនបងបង្អស់ ។

ដារី : តើប្រុសប៉ុន្មានស្រីប៉ុន្មាន?

ប៊ុយ : បងប្អូនខ្ញុំ៩នាក់ ប្រុស៧ ស្រី២ ។

ដារ៉ា : នៅទាំងអស់?

ប៊ុយ : បាទ! នៅទាំងអស់ មានតែប្អូនទេ ដែលគ្រប់គ្រង ប្អូនស្រី ។

ដារី : បន្ទាប់ពីពូ?

ប៊ុយ : ទេ បន្ទាប់ពីខ្ញុំមកក៏មិនបាននៅដែរ ព្រោះចូលចល័ត ។

ដារ៉ា : ចូលចល័ត?

ប៊ុយ : បាទ! ដូច្នេះមានតែប្អូនស្រី១ទេ ដែលនៅតូចហើយគ្រប់គ្រង ។ ហើយប្អូនខ្ញុំអីប្រុសៗនៅតូចណាស់ ។

ដារ៉ា : អីចឹងចុងក្រោយ... ។

ដារី : ចង់សួរថាពីដំបូងឡើងហេតុអីបានជាពូទៅធ្វើចល័ត តើពូទៅធ្វើដោយស្ម័គ្រចិត្តឬយ៉ាងម៉េច?

ប៊ុយ : អត់ទេ គេរើស គេតម្រូវឲ្យយើង ។ ឧទាហរណ៍ថាមួយភូមិនេះ យុវជនប៉ុន្មាន ឧទាហរណ៍ថា ៣០នាក់ ដូច្នេះគេប្រជុំ ឥឡូវដក២០នាក់ទៅចល័ត ដូច្នេះគេចុចឈ្មោះយើងហើយ ថាឈ្មោះណាៗ គេចែក ហើយគេរើសទៅ យើងទៅតាមគេ ហើយយើងទៅដោយអារម្មណ៍គិតថាមិនដឹងទៅស្លាប់មិនដឹងទៅរស់ ពេលគេដកទៅ វាភ័យលុះទៅដល់ការដ្ឋានក្ដាម ចាប់ចបចាប់ដីនឹកទើបដឹងថាយើងរស់ ។ កាលមុននឹងយើងមិនដឹងថាខ្លួនស្លាប់ឬរស់ទេពេលដែលគេដកទៅយើងភ័យរៀងៗខ្លួន ។

ដារ៉ា ៖ អ៊ីចឹងអរគុណច្រើនពូដែលបានផ្ដល់ព័ត៌មាន ។

ប៊ុយ ៖ ហើយពូបើសិនជាពួកខ្ញុំយកព័ត៌មានដែលពូបានផ្ដល់ឲ្យពួកខ្ញុំយកទៅផ្សព្វផ្សាយ តើពូគិតយ៉ាង ម៉េចដែរ?

ប៊ុយ ៖ ទេមិនទាស់អីទេ ការផ្សព្វផ្សាយនេះ អត់ទាស់ទេ ត្រេកអរណា ដើម្បីឲ្យក្មេងក្រោយៗដឹងថា របបនោះល្វឹងជូរចត់យ៉ាងម៉េចណា ទើបកូនក្មេងចងចាំទុក ។

យាង ៖អរគុណច្រើនពូ ។

ប៊ុយ ៖ បាទ!

«ចប់»